CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 26 ខែមករា ឆ្នាំ 2021

ទំនាក់ទំនង ៖ លោក Rick de la Torre មន្ត្រីព័ត៌មានសហគមន៍នាយកដ្ឋានសេវាអភិវឌ្ឍន៍,
562.570.7174, Richard.delaTorre@longbeach.gov

សម្រាប់ការផ្សព្វផ្សាយ ភ្លាមៗ

# សាលាក្រុងឡុងប៊ិច ធ្វើប្រព័ន្ធចាប់ឆ្នោតសម្រាប់ការចុះឈ្មោះ សម្រាប់ការជួលរយៈពេលខ្លី មិនមែនជាលំនៅដ្ឋានបឋម

*ពាក្យសុំសម្រាប់ការចាប់ឆ្នោត នឹងត្រូវបានទទួលយកចាប់ពីថ្ងៃទី 28 ខែមករា*

ទីក្រុងឡុងប៊ិច, រដ្ឋ CA - បានប្រកាសនៅថ្ងៃនេះថាខ្លួននឹងធ្វើការចាប់ឆ្នោតដោយចៃដន្យ ដើម្បីបង្កើតបញ្ជីចុះឈ្មោះអាទិភាពសម្រាប់ការជួលរយៈពេលខ្លី មិនមែនជាលំនៅដ្ឋានបឋមដែលត្រូវបានអនុញ្ញាតក្រោម បញ្ញត្តិ ថ្មីអនុម័តដោយក្រុមប្រឹក្សាក្រុងឡុងប៊ិច។ បេក្ខជនឆ្នោត 800 នាក់ដំបូងដែ លត្រូវបានជ្រើសរើសនឹងទទួលបានការកក់ដែលបន្ទាប់មកអាចត្រូវបានប្រើ ដើម្បីចុះឈ្មោះការជួលរយៈពេលខ្លី មិនមែនជាលំនៅដ្ឋានបឋមរបស់ពួកគេ ស្របច្បាប់ជាមួយសាលាក្រុង។

អភិបាលក្រុងលោក Robert Garcia បានមានប្រសាសន៍ថា «ការជួលរយៈពេលខ្លីអាចផ្តល់នូវអត្ថប្រយោជន៍ និងឱកាសជាច្រើនសម្រាប់ពលរដ្ឋ និងភ្ញៀវទេសចរ ។» «កម្មវិធីនេះនឹងជួយធានាថាការជួល និងរស់រយៈពេលខ្លីនៅទូទាំងទីក្រុងមានសុវត្ថិភាព និងរក្សាភាពរស់នៅរបស់សហគមន៍របស់យើង។»
នាយកដ្ឋានសេវាកម្មអភិវឌ្ឍន៍នឹងចាប់ផ្តើមទទួលយកពាក្យសុំតាមអ៊ិនធឺណេតសម្រាប់ការចាប់ឆ្នោតនៅថ្ងៃទី 28 ខែមករា ឆ្នាំ 2021 វេលាម៉ោង 8:30 ព្រឹក។ ការចូលរួមនឹងត្រូវបានទទួលយកប្រមាណជា 3 សប្តាហ៍ហើយនឹងបិទនៅថ្ងៃទី 17 ខែកុម្ភៈ ឆ្នាំ 2021 វេលាម៉ោង 11:59 នាទី។ ការចាប់ឆ្នោតចៃដន្យនឹងត្រូវបានធ្វើឡើងភ្លាម និងធ្វើឡើងដូចខាងក្រោម៖

- ពាក្យសុំ 800 ដំបូងដែលចាប់ឆ្នោតត្រូវចំ នឹងទទួលបានការកក់ដើម្បីចុះឈ្មោះ។
- អ្នកចូលរួមទាំងអស់នឹងត្រូវបានជូនដំណឹងអំពីលទ្ធផលបុគ្គលរបស់ពួកគេតាមរយៈអ៊ីម៉ែល និងផ្តល់ព័ត៌មានអំពីជំហានបន្ទាប់។
- ការចូលដែលត្រូវចាប់បានបន្ទាប់ពីលេខ 800 ដំបូងនឹងត្រូវដាក់ក្នុងបញ្ជីរង់ចាំការកក់ទុកជាមុនតាមលំដាប់លំដោយ។

ព័ត៌មានលម្អិតអំពីការចាប់ឆ្នោត រួមជាមួយទម្រង់ពាក្យសុំអេឡិចត្រូនិចមាននៅក្នុងគេហទំព័រកម្មវិធី STRs។ សម្រាប់ជំនួយ ម្ចាស់អចលនៈទ្រព្យ ឬប្រតិបត្តិករអាចទូរស័ព្ទមកលេខ 562.570.6820 ឬអ៊ីម៉ែល shorttermrentals@longbeach.gov។

CITY OF LONG BEACH

# PRESS RELEASE

បន្ទាប់ពីការចាប់ឆ្នោត, បុគ្គលិកសាលាក្រុងនឹងចាប់ផ្តើមទទួលយក និងដំណើរការពាក្យសុំកក់ទុកមុន ដោយមកមុន បានមុន។ ប្រសិនបើបញ្ជីរង់ចាំត្រូវបានបង្កើតឡើង វានឹងត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់។

ដំណើរការសម្រាប់ការចុះឈ្មោះទីលំនៅបឋម STRs បានដំណើរការរួច ហើយនឹងបន្តដោយគ្មានការរំខាន។ លើសពីនេះទៀត, សាលាក្រុងនេះនៅតែបន្តរក្សាបញ្ជីឈ្មោះម្ចាស់អចលនៈទ្រព្យ អគារ ផ្ទះ អាផាតមិន និងសមាគមម្ចាស់ផ្ទះ (HOAs) នៅឡុងប៊ិច ដែលចង់ហាមឃាត់អ្នកណាម្នាក់មិនឱ្យទទួលបានការចុះឈ្មោះបឋម STR លើអចលនទ្រព្យរបស់ពួកគេ។ ព័ត៍មានបន្ថែមអំពីការចុះឈ្មោះទីលំនៅបឋមអាចត្រូវបានរកឃើញនៅលើគេហទំព័រ STRs។

ដូចដែលបានបង្កើតឡើងតាមរយៈបទបញ្ញត្តិ ប្រតិបត្តិករដែលមាន STRs មិនបានចុះឈ្មោះទាំងបឋម និងមិនមែនបឋម, មានរហូតដល់ថ្ងៃទី 22 ខែមេសា ឆ្នាំ 2021 ដើម្បីចុះឈ្មោះជាមួយសាលាក្រុង។

ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធី STRs រួមមានព័ត៍មានអំពីគោលការណ៍ណែនាំ STR ដើម្បីជួយធានាសុវត្ថិភាព និងភាពរស់នៅរបស់ភូមិដ្ឋាននៅឡុងប៊ិច សូមចូលទៅកាន់គេហទំព័រ longbeach.gov/strs។ សាលាក្រុងក៏រក្សាផងដែរនូវបណ្តាញទូរស័ព្ទទទួលបណ្តឹង STR ។ ប្រជាជនអាចរាយការណ៍អំពីកង្វល់ ឬសកម្មភាពរំខានផ្សេងៗ តាមប្រព័ន្ធអ៊ីនធឺណិត ឬដោយទូរស័ព្ទទៅកាន់លេខ 562.568.8665 ។

សម្រាប់ព័ត៍មានបន្ថែមអំពីលំនៅដ្ឋាននៅ Long Beach សូមចូលទៅ longbeach.gov/lbds ឬមើលធនធាន របស់សាលាក្រុងសម្រាប់ម្ចាស់ផ្ទះ, អ្នកជួលផ្ទះ និងម្ចាស់ផ្ទះ។

# # #